# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាជាមួយបូជាចារ្យនៅភ្នំពេញថ្មី
# ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨

*ជីវិតរបស់អ្នកដ៏វិសុទ្ធ*

អត្ថបទទី១៖ កក ១២,១-១
អត្ថបទទី២៖ ២ធម ៤,៦-៨.១៧-១៨
ដំណឹងល្អ៖ មថ ១៦,១៣-១៩

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពសន្តសិលា និងសន្តប៉ូល ជាគ្រីស្តទូត ជាសរសរនៃព្រះសហគមន៍ បានណែនាំឲ្យព្រះសហគមន៍មានជីវិតរហូតដល់សព្វថ្ងៃ ដោយសារគេបានសុខចិត្ត ចាក់មូលដ្ឋានគ្រឹះទៅលើព្រះយេស៊ូ។ សន្តប៉ូល ដែលបានធ្វើដំណើរ សន្តសិលា ដែលបានយកចិត្តទុកដាក់ប្រកាសដំណឹងល្អនៅទីក្រុងរ៉ូម ណែនាំឲ្យយើងត្រូវតែនឹកឃើញដល់ជីវិតនៃព្រះសហគមន៍យើង។ ពីសម័យដើម សន្តប៉ូល និងន្តសិលា បានដើរតាមព្រះយេស៊ូពីរបីឆ្នាំ បានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូពីមួយថ្ងៃទៅមួយថ្ងៃ រហូតអាចប្រកាសអស់ពីដួងចិត្ត សន្តសិលាថា "**ព្រះយេស៊ូជាព្រះគ្រីស្ត ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់**"។ នេះជាជំនឿដែលគាត់បានទទួលពីព្រះបិតាជាទីស្រឡាញ់ គាត់មិនចេះតែប្រកាសដូចប្រជាជនទូទៅ ប៉ុន្តែលោកសិលាបានចូលយ៉ាងជ្រៅនៅក្នុងអំណោយទាន ដែលគេបានទទួលពីថ្ងៃដែលព្រះយេស៊ូបានជ្រើសរើសគាត់ឲ្យទៅនេសាទមនុស្ស។

លោកប៉ូល បានយកចិត្តទុកដាក់រស់នៅតាមធម៌វិន័យរបស់សាសនាយូដា គាត់បានបៀតបៀនគ្រីស្តបរិស័ទ នៅពេលព្រះជាម្ចាស់បានជ្រើសរើសគាត់ឲ្យកែប្រែចិត្តគំនិត ជីវិតរបស់គាត់ទៅជាជីវិតដែលយកចិត្តទុកដាក់នៅក្នុងរបៀបប្រកាសដំណឹងល្អ ជាពិសេសឲ្យសាសនដទៃអាចស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន។ គាត់បានខិតខំណាស់ គាត់បានធ្វើដំណើរ បានជាប់គុក បានទទួលការបៀតបៀន បានទទួលការរិះគន់ តស៊ូចិញ្ចឹមជីវិតខ្លួនឯង លើកទឹកចិត្តគ្រីស្តបរិស័ទ រហូតដល់ទីក្រុងរ៉ូមគាត់ទទួលមរណភាព។

ថ្ងៃនេះ ជាឱកាសមួយដើម្បីគិតអំពីជីវិតរបស់យើង ដែលជាបូជាចារ្យ ដែលជាព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ យើងមានសន្តសិលា សន្តប៉ូល និងសន្តសន្តីជាច្រើនជាគំរូ ដើម្បីឲ្យយើងដើរតាមព្រះយេស៊ូ។ សន្តនីមួយៗណែនាំឲ្យយើងចូលនៅក្នុងជីវិតរបស់ព្រះជាម្ចាស់ ដែលជាជីវិតដ៏វិសុទ្ធ។ ជីវិតដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ សម្រាប់យើងទាំងអស់គ្នាទាំងបូជាចារ្យ ទាំងបងស្រី ទាំងបងប្រុស ទាំងគ្រីស្តបរិស័ទ ធ្វើយ៉ាងណាដើម្បីឲ្យយើងភ្ជាប់ជាមួយព្រះជាម្ចាស់ ដូចយើងបានភ្ជាប់ពីថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក។ សម្តេចប៉ាប បានសរសេរសារលិខិតមួយជូនដល់គ្រីស្តបរិស័ទទូទាំងពិភពលោក ដើម្បីធ្វើជាអ្នកដ៏វិសុទ្ធនៅលើផែនដីនេះ ដើម្បីចូលនៅក្នុងព្រះហឫទ័យព្រះជាម្ចាស់នៅស្ថានបរមសុខ។ សម្តេចប៉ាប ចាប់ផ្តើមធ្វើដំណើរ ដោយនឹកឃើញធម្មទេសនារបស់ព្រះយេស៊ូ អំពីសុភមង្គលដ៏ពិតប្រាកដ ដោយសារទ្វារនៃជីវិតជាអ្នកដ៏វិសុទ្ធ ទ្វារនៃជីវិតជាគ្រីស្តបរិស័ទ គឺដាក់ចិត្តជាអ្នកក្រខ្សត់។ សុខចិត្តលះបង់

ដើម្បីណែនាំឲ្យព្រះជាម្ចាស់មានទីតាំងនៅក្នុងដួងចិត្តរបស់យើង កុំឲ្យយើងពោរពេញដោយគំនិតដែលមកពីលោកីយ៍ កុំឲ្យយើងពោរពេញដោយអ្វីៗទាំងអស់ ដែលណែនាំឲ្យយើងមើលមិនឃើញព្រះជាម្ចាស់។

ជីវិតរបស់អ្នកដ៏វិសុទ្ធ ជាអ្នកដែលសុខចិត្តរស់នៅដោយដាក់ចិត្ត មានចិត្តសុភាពរាបសាដើម្បីទទួលស្វាគមន៍បងប្អូនឯទៀតៗ ជាពិសេសកុំឲ្យយើងមានអំនួត។ កុំឲ្យយើងគិតថាមានតែខ្ញុំដែលល្អអ្នកដទៃគ្មានតម្លៃ កុំឲ្យយើងគិតអំពីឋានៈ អ្នកមានចិត្តដ៏វិសុទ្ធគឺអ្នកដែឡរស់នៅក្នុងជីវិតសាមញ្ញធម្មតាជាមួយបងប្អូនឯទៀតៗ។ ឲ្យយើងចេះទទួលស្វាគមន៍ នៅក្នុងរបៀបដែលព្រះយេស៊ូបានទទួលស្វាគមន៍ និងធ្វើដំណើរជាមួយមនុស្សទាំងអស់។ ដោយសារព្រះយេស៊ូមិនខ្លាចអង្គុយជាមួយអ្នកមានបាប មិនខ្លាចទទួលស្វាគមន៍ស្ត្រីសាសន៍សាម៉ារី មិនខ្លាចអង្គុយបរិភោគក្នុងផ្ទះអ្នកទារពន្ធ ព្រះយេស៊ូអង្គុយជាមួយអ្នកក្រីក្រ ជាមួយកូនក្មេង ព្រះយេស៊ូនៅជាមួយមនុស្សគ្រប់ប្រភេទ ដើម្បីបង្ហាញថានៅក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ មានទីលំនៅសម្រាប់មនុស្សទាំងអស់លុះត្រាតែយើងសុខចិត្តកែប្រែចិត្តគំនិត។

អ្នកដែលមានភាពដ៏វិសុទ្ធ គឺអ្នកដែលមានសមត្ថភាព ដើម្បីយំចូលរួមនៅក្នុងទុក្ខលំបាករបស់បងប្អូនឯទៀតៗ។ ឲ្យយើងចេះមើលជីវិតរបស់បងប្អូន ហើយយើងចេះយំជាមួយគេ យើងចេះចូលរួមនៅក្នុងទុក្ខលំបាករបស់គេ ជាពិសេសនៅក្នុងចិត្តរបស់បងប្អូនឯទៀតៗ។ នៅពេលយើងឃើញបងប្អូនដែលកំពុងពិបាក កំពុងមានទុក្ខលំបាក ឲ្យយើងធ្វើយ៉ាងណាដើម្បីចូលរួមយ៉ាងពិតប្រាកដមែន ដោយមានចិត្តតែមួយ។

អ្នកកំពុងរៀបចំខ្លួនជាអ្នកដ៏វិសុទ្ធ ជាអ្នកដែលស្វែងរកយុត្តិធម៌យ៉ាងពិតប្រាកដ ដោយបង្ហាញការអន់ចិត្តនៅពេលឃើញភាពអយុត្តិធម៌។ អ្នកម្តាយតេរេសា គាត់បានស្រេកឃ្លានយុត្តិធម៌ គាត់បាននិយាយយ៉ាងខ្លាំងនៅពេលឃើញអ្នកជំងឺដែលស្លាប់នៅតាមផ្លូវ ដើម្បីឲ្យសង្គមនិងមនុស្សលោកអាចទទួលស្គាល់នេះមិនធម្មតាទេ។ យើងធ្វើយ៉ាងណា ដើម្បីភ្ញាក់ស្មារតីឲ្យយើងស្រេកឃ្លានយុត្តិធម៌យ៉ាងពិតប្រាកដ។ សម្តេចប៉ាប ណែនាំឲ្យយើងចេះបើកភ្នែក ដើម្បីរស់នៅក្នុងការលើកលែងទោសជានិច្ច ឲ្យសកម្មភាពរបស់យើងជាប្រចាំថ្ងៃ ទៅជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់គឺធម៌មេត្តាករុណា។ យើងឃើញរបៀបព្រះយេស៊ូព្រះអង្គបានទតមើលគេដោយមានព្រះហឫទ័យមេត្តាករុណា ដោយព្រះហឫទ័យស្រឡាញ់។ នៅពេលលោកសិលាក្បត់ព្រះយេស៊ូ ពេលមាន់រងាវនៅពេលនោះព្រះយេស៊ូទតមើលលោកសិលា ធ្វើឲ្យលោកសិលាយំដោយសារព្រះយេស៊ូទតមើលគាត់ដោយភ្នែកស្រឡាញ់របស់ព្រះអង្គ។ ដោយសារនេះ ណែនាំឲ្យគាត់កែប្រែចិត្តគំនិតរបស់គាត់ ក្លាយជាអ្នកដឹកនាំព្រះសហគមន៍ដំបូងគេបង្អស់ ក្រោយពីព្រះយេស៊ូប្រទានព្រះសហគមន៍ឲ្យគាត់មើលថែរក្សា។

អ្នកដ៏វិសុទ្ធ គឺថែរក្សាចិត្តបរិសុទ្ធដូចកូនក្មេងម្នាក់ ដែលទីពឹងលើឪពុកម្តាយ សម្រាប់ជីវិតរបស់យើងឲ្យយើងចេះទីពឹងលើព្រះជាម្ចាស់ ដើម្បីថែរក្សាភាពដ៏វិសុទ្ធរបស់យើង។ ព្រះបិតាស្រឡាញ់យើង ព្រះអង្គថែរក្សាយើងជារៀងរាល់ថ្ងៃ។

អ្នកដ៏វិសុទ្ធ មានន័យថាសុខចិត្តសាបព្រោះសេចក្ដីសុខសាន្ត គោលដៅរបស់មនុស្សទាំងអស់នៅក្នុងពិភពលោក គឺធ្វើដូចម្ដេចដើម្បីឲ្យមានសេចក្ដីសុខសាន្តនៅក្នុងជីវិត។ នៅក្នុងពិភពលោករបស់យើងទាំងមូល ប្រសិនបើយើងមានសេចក្ដីសុខសាន្តយើងសប្បាយចិត្តណាស់ ដោយដឹងថាពិតមែនខ្ញុំរស់នៅក្នុងពិភពដែលពោរពេញដោយសេចក្ដីសុខសាន្ត ខ្ញុំកំពុងប្រគល់ពិភពលោកនេះឲ្យកូនចៅរបស់ខ្ញុំ។ យើងបានទទួលទ្រព្យសម្បត្តិពីព្រះជាម្ចាស់ យើងធ្វើដូចម្ដេចដើម្បីឲ្យពិភពលោកនេះរស់នៅក្នុងសេចក្ដីសុខសាន្ត។ ជីវិតរបស់យើងជាគ្រីស្តបរិស័ទ ឲ្យយើងទៅជាគ្រីស្តទូតនៃសេចក្ដីសុខសាន្តពិតមែន យើងជាអ្នកសាបព្រោះឲ្យលូតលាស់ ដើម្បីឲ្យសេចក្ដីសុខសាន្តនៅគ្រប់ទីកន្លែង។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ បីដូចជាគ្រាប់ពូជល្អិតតូចបំផុត ពេលវាធ្លាក់នៅក្នុងដីដោយសារសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ទៅជាដើមឈើមួយយ៉ាងធំ ដែលមានគ្រប់បក្សាបក្សីដែលមកធ្វើសំបុក។

យើងរស់នៅដោយឯកភាព ដោយចូលរួមនៅក្នុងផ្លូវនៃដំណឹងល្អ យើងដើរតាមផ្លូវមិនល្អស្រួលណាស់ ប៉ុន្តែផ្លូវដែលណែនាំឲ្យយើងរស់នៅក្នុងសេចក្ដីសុខ តាមសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចង្អៀតណាស់។ សន្តីតេរេសាធ្លាប់និយាយថា "**ដៃរបស់ព្រះយេស៊ូ បីដូចជាជណ្ដើរយន្តមួយដែលចាប់ខ្ញុំដើម្បីឡើងស្ថានបរមសុខ**"។ ទោះបីផ្លូវនេះចង្អៀតពិតមែន បើយើងទុកឲ្យព្រះជាម្ចាស់ជួយយើងដើម្បីឲ្យយើងទៅមុខ យើងពោរពេញដោយសមត្ថភាព។ នៅពេលព្រះនាងម៉ារីបានឆ្លើយថា "**នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់**" ដូចយើងទាំងអស់បានឆ្លើយយើងជាអ្នកបម្រើរបស់ព្រះជាម្ចាស់ នៅក្នុងចម្លើយហ្នឹងព្រះជាម្ចាស់ប្រទាន អំណាចនិងសមត្ថភាពដើម្បីទៅមុខ ដើម្បីរស់នៅក្នុងផ្លូវនៃសេចក្ដីសុខ នៅក្នុងផ្លូវនៃជីវិតដ៏បរិបូរណ៍ ដូចព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំយាងមកដើម្បីឲ្យគេមានជីវិត ជីវិតដ៏បរិបូរណ៍**"។ អាម៉ែន៕